**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២៧៥.សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីជូនដំណឹងលេខ ១១៥៦ សជណ.ពហ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**ប្រការ ១ ៖** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| **១-ឯកឧត្តម ប៊ិន ឈិន** | ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ប្រធាន |
| **២-ឯកឧត្តម អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី ១ |
| **៣-ឯកឧត្តម ឱម យ៉ិនទៀង** | ទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ | អនុប្រធាន |



www.pheakdeylaw.com

| | | |
|---|---|---|
| ៤-ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧-ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៨-ឯកឧត្តម សាយ សំអាល់ | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៩-ឯកឧត្តម សុខ ចិន្តាសោភា | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០-ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១១-ឯកឧត្តម ទឹករ៉េត សំរេច | រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២-ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៣-ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៤-ឯកឧត្តម ហ៊ុន ម៉ានិត | អគ្គលេខាធិការរងទី ១ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ១៥-ឯកឧត្តម ឆេង គឹមស៊ុន | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១៦-ឯកឧត្តម ចាយ សាមិទ្ធ | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយករដ្ឋបាលការពារ និងអភិរក្សតំបន់ធម្មជាតិ | សមាជិក |
| ១៧-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត ដែលមានសម្បទានដីសេដ្ឋកិច្ច | | សមាជិក |

**ប្រការ ២ ៖** គណៈកម្មការនេះមានភារកិច្ច៖

-ត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ជូនក្រុមហ៊ុនឯកជនកន្លងមក ដើម្បីដកហូតមកវិញចំពោះសម្បទានដីសេដ្ឋកិច្ច ដែលក្រុមហ៊ុនមិនបានបំពេញកាតព្វកិច្ចផ្លូវច្បាប់តាមកិច្ចសន្យា។

-ធ្វើរបាយការណ៍ និងគោរពជូនមតិ សម្តេចនាយករដ្ឋមន្ត្រី ក្នុងការពង្រឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចតាមដំណាក់កាលនីមួយៗ។



www.pheakdeylaw.com

**ប្រការ ៣ ៖** ប្រធានគណៈកម្មការកោះប្រជុំគណៈកម្មការអន្តរក្រសួងនេះ ១៥ ថ្ងៃម្តង។ ក្នុងករណីចាំបាច់គណៈកម្មការអាចប្រជុំជាវិសាមញ្ញបាន។

**ប្រការ ៤ ៖** ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ អាចប្រើប្រាស់មន្ត្រីរបស់ស្ថាប័នខ្លួន ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់គណៈកម្មការអន្តរក្រសួង។

**ប្រការ ៥ ៖** ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ ប្រើប្រាស់ថវិការបស់ស្ថាប័នផ្ទាល់ ដើម្បីផ្តល់ជូនមន្ត្រីដែលបំពេញបេសកកម្មការងាររបស់គណៈកម្មការអន្តរក្រសួង។ ក្នុងករណីចាំបាច់អាចសុំការឧបត្ថម្ភពីរាជរដ្ឋាភិបាល។

**ប្រការ ៦ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- -ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៦
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com